អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២ ខែកក្កដា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# ប្រទេសអូស្ត្រាលីប្រកាសផ្តល់ជំនួយថវិកា
# ចំនួន ៣,២៥ លានដុល្លារអូស្ត្រាលីដល់អ.វ.ត.ក

រដ្ឋាភិបាលអូស្ត្រាលី បានប្រកាសសន្យាផ្តល់វិភាគទានហិរញ្ញវត្ថុថ្មីចំនួន ៣,២៥ លានដុល្លារអូស្ត្រាលី (ប្រមាណ ៣ លានដុល្លារសហរដ្ឋអាម៉េរិក) ជូនដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ ជាមួយការសន្យាថ្មីនេះ ប្រទេសអូស្ត្រាលីបានផ្តល់វិភាគទានហិរញ្ញវត្ថុសរុបចំនួន ជាង ២៦លានដុល្លារអូស្ត្រាលីដល់ អ.វ.ត.ក ។ អូស្ត្រាលីគឺជាម្ចាស់ជំនួយធំទី២ របស់ អ.វ.ត.ក និងបានគាំទ្រតុលាការនេះចាប់តាំងពីការបង្កើតមកម្ល៉េះ។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានមានប្រសាសន៍ថា៖“ខណៈដែលយើងកំពុងរង់ចាំការប្រកាសសាលក្រមលើសំណុំរឿង ០០២/០១ និងការបន្តកិច្ចការលើសំណុំរឿងដែលនៅសេសសល់ វិភាគទាននេះនឹងជួយធានាថាយុត្តិធម៌នឹងអាចផ្តល់ជូនប្រជាជនកម្ពុជាទៅតាមពេលវេលាដែលបានកំណត់។ ប្រទេសអូស្ត្រាលី គឺជាដៃគូដែលមិនអាចខ្វះបាននៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ចាប់តាំងពីការបង្កើតតុលាការ ហេតុដូច្នេះ អ.វ.ត.ក សូមសម្តែងនូវអំណរគុណយ៉ាងជ្រៀលជ្រៅជាទីបំផុត”។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (០) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh